# មហាសង្ក្រាន្ត ឆ្នាំម្សាញ់ បញ្ចស័ក
# ចុល្លសករាជ ១៣៧៥ មហាសករាជ ១៩៣៥
# ពុទ្ធសករាជ ២៥៥៧ គ្រឹស្តសករាជ ២០១៣

## សុភមស្តុ! វរមង្គលាជយាតិរេក

ព្រះពុទ្ធសករាជព្រះសាសនា អតិក្កន្តាកន្លងទៅហើយបាន ២៥៥៦ ព្រះវស្សាត្រឹមថ្ងៃពេញបូណ៌មី ខែពិសាខ លុះដល់ថ្ងៃ ១រោច ខែពិសាខ ចូលព្រះពុទ្ធសករាជ ២៥៥៧ ព្រះវស្សាតទៅ។

និងគណនាឆ្នាំម្សាញ់ ឥឡូវនេះ **សង្ក្រាន្តចូលមកនៅថ្ងៃអាទិត្យ ៤កើត ខែចេត្រត្រូវនឹងថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៣ វេលាម៉ោង ២:១២នាទី រំលងអធ្រាត្រ** នោះព្រះអាទិត្យចរចេញពីមីនរាសី ទៅស្ថិតនៅមេសរាសី ដើរតាមគោវិថី គឺផ្លូវកណ្តាល ទើបមានទេពធីតាមួយព្រះអង្គជាមគ្គនាយិកាព្រះនាម **ទុង្សាទេវី គង់នៅចាតុម្មហារាជិកា ទ្រង់អម្ពរពណ៌ក្រហម សៀតផ្កាទទឹម គ្រឿងប្រដាប់បទុមរាគ ភក្សាហារផ្លែឧទុម្ពរ(ផ្លែល្វា) ព្រះហស្តស្តាំទ្រង់កងចក្រ ព្រះហស្តឆ្វេងទ្រង់ស័ង្ខ គង់លើត្រុឌជាពាហនៈ** នាំអស់ពួកទេពនិករបរិវារកញ្ញាទាំងមួយសែនកោដិ ហោះទៅកាន់គុហាកែវឈ្មោះធម្មមាលី នាទីភ្នំកៃលាស ខេត្តហិមពាន្ត ដែលប្រតិស្ឋានទុកព្រះសិរសាកបិលមហាព្រហ្ម តម្កល់លើពានមាស នាំចេញមកដង្ហែប្រទក្សិណភ្នំសុមេរុរាជជុំចក្រវាឡ តាមផ្លូវព្រះអាទិត្យចរជាគម្រប់៦០នាទី ហើយដង្ហែចូលទៅតម្កល់ទុកដូចដើមវិញ ទើបប្រជុំទេវបុត្រទេវធីតាទាំងមួយសែនកោដិ ចូលទៅស្រង់ទឹកអនោតត្តមហាស្រះ ដែលមានទឹកហូរចេញពីបំពង់ថ្មកែវទាំង៧ ជាមាត់គោឧសភរាជ ត្រជាក់ត្រជុំក្សេមក្សាន្តព្រះហឫទ័យ ទើបនាំគ្នាចូលទៅសមាទានសីល ដោយព្រះទ័យសោមនស្សរីករាយគ្រប់ៗអង្គ ក្នុងភគវតីសភាដែលវិសកម្មទេវបុត្រនិម្មិតថ្វាយ ហើយបន្ទោបង់នូវអពមង្គល ឱ្យជ្រះស្រឡះ ចម្រើននូវសុភមង្គល សិរីសួស្តី ជន្មាយុយឺនយូរតរៀងទៅ។

*-ថ្ងៃអាទិត្យ ៤កើតខែចេត្រ ត្រូវនឹងថ្ងៃ១៤ មេសា ឆ្នាំ២០១៣ ម៉ោង២:១២នាទីរំលងអធ្រាត្រជាថ្ងៃចូល។*
*-ថ្ងៃចន្ទ ៥កើតខែចេត្រ ត្រូវនឹងថ្ងៃ ១៥ មេសា ឆ្នាំ២០១៣ ជាថ្ងៃ វនប័ត។*
*-ថ្ងៃអង្គារ ៦កើត ខែចេត្រ ត្រូវនឹងថ្ងៃ១៦ មេសា ឆ្នាំ២០១៣ ជាថ្ងៃឡើងស័ក។ គម្រប់សង្ក្រាន្ត៣ថ្ងៃស្រេចបរិបូណ៌ ចូលជាសកលឆ្នាំម្សាញ់តទៅ។*

ក្នុងឱកាសសង្ក្រាន្តទាំងបីថ្ងៃនេះ សូមអស់ជនានុជនប្រុសស្រីទាំងឡាយរៀបចំគ្រឿងសក្ការបូជា មានទៀន ធូប ផ្កាភ្ញីថ្វាយព្រះរតនត្រ័យ និងនំចំណីមានផ្លែឈើជាដើមជូនមាតាបិតា អាណាព្យាបាលជាបុព្វការី ព្រមទាំងទទួលស្វាគមន៍ទេវតាឆ្នាំថ្មី ហើយ**ខិតខំលះបង់នូវចិត្តអាក្រក់ ជាចិត្តប្រកបដោយ អភិជ្ឈា ព្យាបាទ មិច្ឆាទិដ្ឋិ ឱ្យជ្រះស្រឡះ ចម្រើនឡើងវិញនូវចិត្តប្រកបដោយបញ្ញា និងព្រហ្មវិហារធម៌គឺ មេត្តា ករុណា មុទិតា ឧបេក្ខា ធ្វើបុណ្យសុន្ទរ៍ទាន រក្សាសីលតាមប្រពៃណីឱ្យបានជាប់ជានិច្ច** នោះទេព្តានឹងឱ្យពរសព្វសាធុការ លោកអ្នកនឹងទទួលសិរីសួស្តី សុភមង្គល វិបុលសុខគ្រប់ប្រការ ប្រកបការងារបានត្រជាក់ត្រជុំអាយុយឺនយូរតរៀងទៅ។

## រណ្តាប់ទទួលទេវតា

រណ្តាប់ទទួលទេវតា តាមទំនៀមពីបុរាណរៀងរហូតមក មានរានទទួល ទេវតាមួយ សម្រាប់តាំងគ្រឿងពលីការផ្សេងៗ ។ ត្រូវរៀបក្រាលសំពត់ពណ៌ស ហើយរៀបបាយសី៩ថ្នាក់មួយគូ បាយសី៧ថ្នាក់មួយគូ បាយសី៥ថ្នាក់មួយគូ បាយសី៣ថ្នាក់មួយគូ បាយសីប៉ាក់ឆាមមួយគូ ស្លាធម៌មួយគូ ទឹកអប់មួយគូ ទៀន៥ ធូប៥ លាជ៥ ផ្កា៥ បារីស្លាម្លូដាក់លើជើងពាន១ ផ្លែឧទុម្ពរ (ផ្លែល្វា) និងដូងខ្ចីមួយគូ ។

*«ដកស្រង់ចេញពីសៀវភៅមហាសង្ក្រាន្ត បោះពុម្ពដោយគណៈកម្មការវិជ្ជាហោរាសាស្ត្រ និងទំនៀមទម្លាប់នៃក្រសួងធម្មការនិងសាសនា»*